# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ០៤៣/១៨ ក.ស.ភ.

ថ្ងៃ សុក្រ ៣កើត ខែ មាឃ ឆ្នាំរកា ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា គ.ស. ២០១៨

# សេចក្តីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ យោងតាមការសម្រេចក្នុងសម័យប្រជុំលើកទី៦ អាណត្តិទី៦ នាថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាល ក.ស.ភ. បានសម្រេចធ្វើការជ្រើសយកក្រុមហ៊ុនសវនកម្មឯករាជ្យ ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត (BDO) ដើម្បីធ្វើជាសវនករឯករាជ្យថ្មីរបស់ ក.ស.ភ. សម្រាប់រយៈពេល ៣ (បី) ឆ្នាំ ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២០ ។ ជាមួយគ្នានេះ ក្រុមប្រឹក្សាភិបាលបានសម្រេចឲ្យ ក.ស.ភ. ធ្វើការចរចាលើលក្ខខណ្ឌសំខាន់ៗនៅក្នុងកិច្ចព្រមព្រៀងដំបូងមុននឹងចុះហត្ថលេខា។ បន្ទាប់ពីការចរចាលើលក្ខខណ្ឌទាំងនោះរួចមក ក.ស.ភ. និងក្រុមហ៊ុន BDO បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការ ដើម្បីទទួលយកក្រុមហ៊ុន BDO ជាសវនករឯករាជ្យថ្មីនាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**